ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
## ស្តីពី
## លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែវិច្ឆិកា និងទិសដៅការងារខែធ្នូ ឆ្នាំ២០១៧

**សេចក្តីផ្តើម** :

នៅក្នុងខែវិច្ឆិកានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម និង មមាញឹកលើគ្រប់ការដ្ឋាន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្ត មុខងាររបស់ខ្លួនបានល្អប្រសើរតាមរយៈលទ្ធផលសំខាន់ៗដូចខាងក្រោម៖

**I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា:**

**១.មុខងារនីតិកម្ម:**

| *រចនាសម្ព័ន្ធនយោបាយ* | *រចនាសម្ព័ន្ធរដ្ឋបាល* |
|---|---|
| - ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក និងប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក ដើម្បីពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន០៤ច្បាប់<br>- បានរៀបចំប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភា ជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន០៤ច្បាប់។ | - បានចាត់ចែងនីតិវិធី ឯកសារពាក់ព័ន្ធ ធ្វើកំណត់ហេតុសង្ខេប និងពិស្តារនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រជុំពេញអង្គព្រឹទ្ធសភា<br>- បានរៀបចំសាល ផ្តល់សេវាភេសជ្ជៈ និងអាហារសម្រាប់ចំនួន១០លើក មានអ្នកចូលរួមចំនួន៥៣៥នាក់<br>- បានថតចម្លងឯកសារបានចំនួន២,២៥០ច្បាប់ អស់ក្រដាសចំនួន៤៨,២៥០សន្លឹក<br>- ធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៩នាក់ ស្មើនឹង០២ច្បាប់<br>- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗ ដោយប្រើប្រាស់កម្លាំងសន្តិសុខ |



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

| | |
|---|---|
| | ផ្ទៃក្នុង និងកម្លាំងអន្តរាគមន៍ពីខាងក្រៅស្ថាប័ន ចំនួន១៨២នាក់ ស្មើនឹង០៥លើក<br>- បានទូទាត់ថ្លៃអាហារសម្រន់ ឧបត្ថម្ភគណៈកម្មការ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន១១លើក<br>- បានទទួលសេចក្តីព្រាងច្បាប់ចំនួន១៣ច្បាប់ ពីរដ្ឋសភា និងរាជរដ្ឋាភិបាល និងបានចាត់ចែងតាមនីតិវិធី<br>- បានធ្វើកំណត់បង្ហាញលើព្រះរាជក្រម ព្រះរាជ-ក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច ប្រកាស ដីកាអម និងលិខិតផ្សេងៗចំនួន៦២ច្បាប់<br>- បានធ្វើបច្ចុប្បន្នភាពប្រតិទិនសម័យប្រជុំព្រឹទ្ធសភា និងបញ្ជីច្បាប់ដែលព្រឹទ្ធសភាបានពិនិត្យ និងឲ្យយោបល់តាមឆ្នាំ និងនីតិកាល<br>- បានរៀបចំឯកសារជំនួយស្មារតីចំនួន០២ច្បាប់ និងកំពុងបន្តសិក្សាស្រាវជ្រាវលើប្រធានបទសំខាន់ៗពាក់ព័ន្ធនឹងតម្រូវការចាំបាច់របស់ស្ថាប័នចំនួន ០៨ច្បាប់<br>- បានរៀបចំតួនាទី ភារកិច្ចរបស់លេខាធិការដ្ឋាន អមគណៈកម្មការក្រមសីលធម៌សភារបស់ព្រឹទ្ធសភា<br>- បានសិក្សាស្រាវជ្រាវ និងសង្ខេបព័ត៌មានប្រចាំថ្ងៃ អំពីសភាប្រទេសនានា<br>- បានរៀបចំទីកន្លែងប្រជុំចំនួន០៥លើក ប្រចាំការថតសំឡេង ថតវីដេអូ និងរៀបចំប្រព័ន្ធសំឡេង ចំនួន១៧លើក<br>- បានថត និងផ្សព្វផ្សាយព័ត៌មាន សេចក្តីជូនដំណឹង សេចក្តីប្រកាសព័ត៌មានចំនួន១៣លើក |

| | |
|---|---|
| | - បានបញ្ចូលឯកសារច្បាប់របស់ព្រឹទ្ធសភា នីតិកាលទី១ និងទី២ ក្នុងគេហទំព័រ E-library ព្រឹទ្ធសភា ។ |

## ២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា:

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សមាជិក សមាជិកាព្រឹទ្ធសភាបានៈ<br>+ អញ្ជើញជួបពិភាក្សាការងារជាមួយប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ទទួលបន្ទុកផ្នែកច្បាប់ នីតិវិធីតុលាការ និងកិច្ចការសន្តិសុខ នៃព្រះរាជាណាចក្រថៃឡង់ដ៍ ដើម្បីឈ្វេងយល់ និងផ្លាស់ប្តូរបទពិសោធន៍អំពីការងារនីតិកម្មព្រឹទ្ធសភា និងវិស័យជាសមត្ថកិច្ចរបស់ខ្លួន<br>+ អញ្ជើញចុះបេសកកម្ម ដើម្បីជួបសំណេះសំណាលផ្លាស់ប្តូរយោបល់គ្នារវាងថ្នាក់ដឹកនាំឃុំ សង្កាត់ និងខេត្តនីមួយៗ ដើម្បីស្វែងរកដំណោះស្រាយ និងចំណុចល្អៗសម្រាប់បំពេញសេចក្តីត្រូវការចាំបាច់របស់ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត<br>+ អញ្ជើញចុះជួបសំណេះសំណាល និងផ្សព្វផ្សាយលទ្ធផលនៃសន្និសីទលើកទី៦ នៃគណៈកម្មាធិការកិច្ចការបរទេសនៃសភាប្រទេសកម្ពុជា ឡាវ វៀតណាម នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ ជូនដល់ថ្នាក់ដឹកនាំនៃខេត្ត ក្រុង ស្រុក បណ្តាមន្ទីរជុំវិញខេត្ត និងក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់នៃខេត្តមណ្ឌលគិរី ។ | - បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០៨នាក់ ស្មើនឹង០២ច្បាប់<br>- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមបណ្តាខេត្ត និងរាជធានីភ្នំពេញទាំង៨ភូមិភាគចំនួន០៥នាក់ ស្មើនឹង០១លើក ។ |

៣.មុខងារតំណាង :

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភាបាន៖<br>+ អញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ក្រោមព្រះរាជធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅព្រះពន្លាខាងមុខព្រះបរមរាជវាំង<br>+ អញ្ជើញជាអធិបតីក្នុងពិធីបំពាក់គ្រឿងឥស្សរិយយសជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា<br>+ អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៦៤ នៃទិវាបុណ្យឯករាជ្យជាតិ៩ វិច្ឆិកា (ព្រះរាជពិធីប្រទានភ្លើងជ័យ) និងព្រះរាជពិធីពន្លត់ភ្លើងជ័យ ក្រោមព្រះរាជធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា<br>+ អញ្ជើញចុះពិនិត្យទិដ្ឋភាពនៃការហ្វឹកហាត់សមរបស់ក្រុមកីឡាករទូកង តៀមចូលរួមប្រកួតក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក<br>+ អញ្ជើញចុះជួបសួរសុខទុក្ខប្រជាពលរដ្ឋ | - រៀបចំបែបបទ ផ្តល់សេវា អមដំណើរថ្នាក់ដឹកនាំសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះមូលដ្ឋានចូលរួមក្នុងកិច្ចប្រជុំ និងជាគណៈអធិបតីក្នុងពិធីផ្សេងៗសរុបចំនួន២៤៨លើក<br>- បានផ្តល់សេវារដ្ឋបាល ពិធីការ និងទំនាក់ទំនងក្នុងដំណើរការរៀបចំកិច្ចប្រជុំ ការចុះស្រាវជ្រាវប្រមូលព័ត៌មាន ពិភាក្សាការងារ ការរៀបចំវេទិកា និងបានរៀបចំពិធីសម្ពោធអគារសិក្សា ១ខ្នង មាន៥បន្ទប់ ព្រមទាំងកម្មវិធីផ្សេងៗ នៅខេត្តកណ្តាល កំពង់ចាម ព្រះវិហារ កំពង់ធំ រតនគិរី និងខេត្តមណ្ឌលគិរី<br>- បានតុបតែងលម្អ ចងបដា ពាក្យស្លោក ចងទង់ជាតិធ្វើហ្វុងអក្សរ ដើម្បីរៀបចំទទួលគណៈប្រតិភូសិក្ខាសាលា ពិធីបុណ្យជាតិ បុណ្យសាសនា បុណ្យអន្តរជាតិ និងពិធីបុណ្យផ្សេងៗចំនួន០៤លើក<br>- បានចុះសួរសុខទុក្ខនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០២នាក់<br>- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១០៤នាក់ ស្មើនឹង៣០ច្បាប់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិកព្រឹទ្ធសភាចំនួន១៥រូប ស្មើនឹង១៥ច្បាប់<br>- បានថតចម្លងឯកសារបានចំនួន៨៧ច្បាប់ អស់ក្រដាសចំនួន៤,៩៦២សន្លឹក<br>- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ |

| | |
|---|---|
| និងអាជ្ញាធរ នៅខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ<br>+ អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបូជាសព លោកជំទាវ លន់ ចន្ទរស្មី នៅវត្តទួលទំពូង រាជធានីភ្នំពេញ<br>+ អញ្ជើញចុះជួបសំណេះសំណាល និងពិភាក្សាការងារជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនឃុំ មកពីទូទាំងខេត្តតាកែវ និងបង្ហាញបេក្ខភាព ដែលនឹងត្រូវឈរឈ្មោះជាសមាជិក សមាជិកាព្រឹទ្ធសភាប្រចាំភូមិភាគទី៥ ដោយមានការអញ្ជើញចូលរួមពីសមាជិកព្រឹទ្ធសភា រដ្ឋសភា ទីប្រឹក្សាឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា ប្រធានក្រុមប្រឹក្សាខេត្ត ថ្នាក់ដឹកនាំជុំវិញខេត្ត និងអភិបាលខេត្តតាកែវ កែប និងខេត្តកំពត<br>+ អញ្ជើញជាអធិបតីក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់អគារសិក្សា១ខ្នង មាន៥បន្ទប់ ដែលជាអំណោយរបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៣ ជូនដល់អនុវិទ្យាល័យព្រះពុទ្ធ នៅខេត្តកណ្ដាល<br>+ អញ្ជើញជាអធិបតី ក្នុងពិធីជប់លៀងជាកិត្តិយសជូនដល់គណៈប្រតិភូរដ្ឋសភានីតិប្បញ្ញត្តិជាតិ នៃព្រះរាជាណាចក្រថៃ-ឡង់ដ៍ ដឹកនាំដោយ ឯកឧត្តមឧត្តមនាវីឯក Sithawat Wongsuwan ប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ទទួលបន្ទុកផ្នែកច្បាប់នីតិវិធី តុលាការ និងកិច្ចការសន្តិសុខ ដែលបាន | សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមបណ្ដាខេត្ត ក្រុង រាជធានីភ្នំពេញទាំង៨ភូមិភាគចំនួន១៤០នាក់ ស្មើនឹង៤៣លើក<br>- បានទទួលលិខិតចូលចំនួន៧៨២ច្បាប់ និងបញ្ជូនលិខិតចេញចំនួន០៧ច្បាប់<br>- បានផ្ដល់សេវាថវិកាជូនថ្នាក់ដឹកនាំព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗសរុបចំនួន៣២លើក<br>- បានការពារសន្តិសុខ សុវត្ថិភាព សណ្ដាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗ ដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន៦៧នាក់ ស្មើនឹង០៣លើក<br>- បានផ្ដល់អត្ថបទ និងរូបថតចំនួន៣៤៨សន្លឹក ជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅចំនួន១១២នាក់ ធ្វើប័ណ្ណសមាជិកចំនួន១៥នាក់ ខ្ចីសៀវភៅចំនួន៣៦ក្បាល និងសងវិញចំនួន៣២ក្បាល<br>- បានទទួលឯកសារ សៀវភៅ ពីអង្គការ ស្ថានទូត ក្រសួង ស្ថាប័ន គ្រឹះស្ថានអប់រំ សប្បុរសជន និងព្រឹត្តិបត្រ និងទស្សនាវដ្ដី ពីអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៤១៥ក្បាល កាសែតចំនួន១៧៥ច្បាប់<br>- បានផលិតព័ត៌មានទាន់ហេតុការណ៍ និងផលិតវីដេអូសម្រាប់បង្ហោះលើ Alert News ចំនួន១៦៧ប្រធានបទ<br>- បានថត និងផ្សព្វផ្សាយព័ត៌មានផ្សេងៗចំនួន២៦លើក |

| | |
|---|---|
| អញ្ជើញមកបំពេញទស្សនកិច្ចជាផ្លូវរដ្ឋនៅព្រះរាជាណាចក្រកម្ពុជា<br>+ អញ្ជើញទទួលគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌថ្នាក់មហាសេរីវឌ្ឍន៍ពី សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា<br>+ អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបុណ្យខួបរំលឹកគុណ សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម និងលោកជំទាវ នៅខេត្តព្រៃវែង<br>- បានទទួលពាក្យបណ្តឹងចំនួន០៤ករណី ផ្ញើលិខិតអន្តរាគមន៍ទៅស្ថាប័នមានសមត្ថកិច្ចដោះស្រាយចំនួន០៣ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្តឹងរបស់ស្ថាប័នមានសមត្ថកិច្ចចំនួន០១ករណី និងទទួលពាក្យបណ្តឹងជូនជ្រាបចំនួន០៩ករណី ព្រមទាំងឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន០៣នាក់<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្តាខេត្ត ក្រុង រាជធានីភ្នំពេញទូទាំងប្រទេសចំនួន១៣៣លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព ក្រុមប្រឹក្សាឃុំសង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការ | - បានដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃសរុបចំនួន៤៩លើក ។ |

| | |
|---|---|
| អនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន១០២លើក ។ | |

**៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ :**

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សម្តេចប្រធានព្រឹទ្ធសភា បានជួបសម្តែងការគួរសម និងសវនាការជាមួយប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ទទួលបន្ទុកផ្នែកច្បាប់ នីតិវិធីតុលាការ និងកិច្ចការសន្តិសុខ នៃព្រះរាជាណាចក្រថៃឡង់ដ៍ និងឯកអគ្គរដ្ឋទូតសាធារណរដ្ឋកូរ៉េខាងត្បូង<br>- ឯកឧត្តមអនុប្រធានទី២ ព្រឹទ្ធសភា បានជួបសម្តែងគួរសម និងពិភាក្សាការងារជាមួយគណៈប្រតិភូក្រុមមិត្តភាពឡាវ កម្ពុជា ព្រមទាំងជប់លៀងជាកិត្តិយសជូនគណៈប្រតិភូ និងទស្សនាការសម្តែងសិល្បៈចម្រុះកម្ពុជា ឡាវ ដើម្បីអបអរទិវាបង្កើតទំនាក់ទំនងការទូតលើកទី៦១ រវាងកម្ពុជា ឡាវ<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានអនុញ្ញាតឲ្យឯកអគ្គរដ្ឋទូតឡាវ ព្រះភទ្ទបណ្ឌិតោ ភិន វុទ្ធី ព្រះគ្រូចៅអធិការវត្តបុរាណនិវេសន៍ និងនិស្សិតបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិត នីតិជំនួញ និងពន្ធដារ នៅប្រទេសបារាំង | - បានរៀបចំពិធីបដិសណ្ឋារកិច្ច ដំណើរទស្សនកិច្ចផ្លូវការរបស់គណៈប្រតិភូអន្តរជាតិ ឥស្សរជននយោបាយ អគ្គទូត និងអង្គការអន្តរជាតិនានា<br>- បានរៀបចំទីកន្លែងសម្រាប់ជំនួបសម្តែងការគួរសម និងសវនាការចំនួន០៦លើក<br>- បានធ្វើពិព័រណ៍រូបភាពនៅព្រឹទ្ធសភាចំនួន០៤លើក<br>- បានថត និងផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំជួបភ្ញៀវជាតិ អន្តរជាតិ មកបំពេញទស្សនកិច្ចចំនួន៣២លើក<br>- បានរៀបចំសម្អាត តុបតែងសាល បម្រើ និងផ្តល់សេវាភេសជ្ជៈ និងផ្គត់ផ្គង់សម្ភារៈអនាម័យក្នុងពិធីផ្សេងៗចំនួន០៨លើក ស្មើនឹង៨៥នាក់<br>- បានថតចម្លងឯកសារចំនួន៨៧ច្បាប់ អស់ក្រដាសចំនួន២,១៨៧សន្លឹក<br>- បានផ្តល់សេវាដឹកជញ្ជូនជូនថ្នាក់ដឹកនាំ សមាជិកសមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមបណ្តាខេត្ត ក្រុង រាជធានី- |

| | |
|---|---|
| ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចូលរួមប្រជុំក្រុមប្រឹក្សាប្រតិបត្តិលើកទី២ និងមហាសន្និបាតលើកទី១០ របស់សភាតំបន់អាស៊ី( APA) នៅប្រទេសតួកគី និងទៅទស្សនកិច្ចសិក្សានិងដកស្រង់បទពិសោធន៍ការងារនៅរដ្ឋសភានៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។ | ភ្នំពេញទាំង៨ភូមិភាគចំនួន៧២នាក់ ស្មើនឹង៣៨លើក<br>- បានធ្វើកំណត់បង្ហាញ កំណត់ហេតុ កំណត់ទូតសំណើ លិខិតអញ្ជើញ និងលិខិតផ្សេងៗចំនួន ២២លើក<br>- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២៦នាក់ ស្មើនឹង០៩ច្បាប់<br>- បានធ្វើលិខិតទៅក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីសុំជំនួយស្មារតីចំនួន ០២លើក<br>- បានផ្តល់សោហ៊ុយថវិកាជូនថ្នាក់ដឹកនាំព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន១៩លើក<br>- រៀបចំកញ្ចប់ថវិកាដំណើរបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា ទៅបំពេញបេសកកម្មក្រៅប្រទេសចំនួន០២លើក<br>- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗ ដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន៦៧នាក់ ស្មើនឹង០៥លើក<br>- អគ្គលេខាធិការព្រឹទ្ធសភា បានជួបពិភាក្សាការងារជាមួយប្រធានមូលនិធិខុនរ៉ាដអាឌិនណៅអ៊ែ(KAS)<br>- បានទំនាក់ទំនងជាមួយស្ថានទូតឥណ្ឌា ស្ថានទូត-បារាំង ព្រឹទ្ធសភាបារាំង សភាសហព័ន្ធវ៉ាល់ឡូនីព្រុចសែល សមាគមបេសកកម្មសិក្សាអាស៊ី វិទ្យាស្ថានបារាំង និងក្រសួង ស្ថាប័ននានា ដើម្បីសម្រួលដល់កិច្ចការអន្តរជាតិ និងដំណើរទស្សនកិច្ច |

| | |
|---|---|
| | សិក្ខាសាលា បំពេញបេសកកម្មក្នុង និងក្រៅប្រទេស ស្នើសុំអាហារូបករណ៍ វគ្គបណ្តុះបណ្តាល ព្រមទាំងការរៀបចំពិធីផ្សេងៗ ។ |

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| | + បានពិនិត្យផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៤៩២ច្បាប់ ។<br>+ការងារគ្រប់គ្រងបុគ្គលិក:<br>- បានរៀបចំលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការសរុបចំនួន១៥ច្បាប់<br>- ប្រជុំសេចក្តីព្រាងក្រមសីលធម៌មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- ចូលរួមប្រជុំស្តីពី មនុស្សចាស់ ជាមួយក្រសួងសង្គមកិច្ច និងអតីតយុវជន<br>- រៀបចំលេខាធិការដ្ឋានក្រមសីលធម៌ គណៈកម្មការក្រមសីលធម៌ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភានីតិកាលទី៤ ការពិចារណារៀបចំយន្តការរបស់ព្រឹទ្ធសភានីតិកាលទី៤<br>- បានរៀបចំធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងបទបញ្ជាផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- កំពុងចាត់ចែងការបកប្រែជាភាសាបារាំង ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ពង្រឹងសមត្ថភាពព្រឹទ្ធសភាកម្ពុជា (២០១៨-២០២៤) ក្នុងបរិបទព្រឹទ្ធសភានីតិកាលទី៤ (២០១៨-២០២៤)<br>- បានចាត់ចែងការបោះពុម្ពដំណាច់ឆ្នាំ ទិនានុលេខន៍ និងប្រតិទិន |

| | |
|---|---|
| | - ជំរុញការបូកសរុបលទ្ធផលការងារ៣នីតិកាល (១៩៩៩-២០១៧) ។<br>+ការងារបណ្តុះបណ្តាលធនធានមនុស្ស:<br>- កិច្ចសហប្រតិបត្តិការជាមួយដៃគូ ដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស និងអភិវឌ្ឍន៍ស្ថាប័ន<br>- ការបណ្តុះបណ្តាលធនធានមនុស្សក្នុង និងក្រៅប្រទេស សរុបចំនួន០៦វគ្គ មានសិក្ខាកាមចូលរួមចំនួន១៣៨នាក់ សិក្ខាសាលាក្នុងប្រទេសចំនួន០១លើក មានសិក្ខាកាមចូលរួមសរុបចំនួន០២នាក់<br>- មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន០១នាក់ បានទទួលពានរង្វាន់ជាកិត្តិយសពីសមាគមសភាប្រើភាសាបារាំង( APF )<br>- បានសហការជាមួយវិទ្យាស្ថានសភាកម្ពុជា(PIC) បើកវគ្គបណ្តុះបណ្តាលភាសាអង់គ្លេសសម្រាប់មន្ត្រីសភា<br>- បើកវគ្គបណ្តុះបណ្តាលមន្ត្រីរាជការផ្ទៃក្នុងអំពីការងារអន្តរជាតិរបស់សភា ។<br>+ចាត់ចែងការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ: :<br>- ប្រជុំគណៈកម្មការកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ប្រជុំពិនិត្យគម្រោងថវិកាតាមកម្មវិធីឆ្នាំ២០១៨<br>- បានរៀបចំរបាយការណ៍ចំនួនមន្ត្រីក្របខ័ណ្ឌនិងបុគ្គលិកជាប់កិច្ចសន្យា របាយការណ៍ប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់វិភាជន៍ផ្សេងៗ |

| | |
|---|---|
| | និងរបាយការណ៍ចំណាយថវិកាធៀបអាណត្តិប្រចាំខែ ឆ្នាំ២០១៧ ផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- បានទូទាត់ថ្លៃទិញសម្ភារៈ គ្រឿងអេឡិចត្រូនិច គ្រឿងសំណង់ និងទំនិញផ្សេងៗចំនួន៦០លើក<br>- បានលើកគម្រោងទិញវត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារផ្សេងៗ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំនានាចំនួន២០សំណើ និងផ្គត់ផ្គង់សម្ភារៈអនាម័យ សម្ភារៈការិយាល័យ និងភេសជ្ជៈចំនួន៣៥សំណើ ជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានរៀបចំសម្អាត តុបតែងសាល ផ្តល់សេវាភេសជ្ជៈ និងអាហារសម្រន់ក្នុងពិធីផ្សេងៗចំនួន១៥លើក មានអ្នកចូលរួមចំនួន៦៤៣នាក់<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន ១១៦លើក<br>- បានថតចម្លងឯកសារបានចំនួន២,៧៩៨ច្បាប់ អស់ក្រដាសចំនួន១១,៩៥០សន្លឹក<br>- ផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា ក្នុងរាជធានីភ្នំពេញចំនួន ៨០នាក់ ស្មើនឹង៣៦លើក ។<br>+ការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រឹង និងទន់:<br>- រៀបចំបែបបទសុំជំនួយពីសាធារណរដ្ឋប្រជា-មានិតចិន ដើម្បីសាងសង់សាលប្រជុំពេញអង្គថ្មី |

| | |
|---|---|
| | - បានធ្វើបែបបទស្នើសុំជំនួយពីប្រទេសជាមិត្ត សម្រាប់នីតិកាលទី៤ព្រឹទ្ធសភា<br>- ចាត់ចែងជួសជុលសាលប្រជុំពេញអង្គ និងបញ្ចប់ដំណើរការជួសជុលអគារមូលនិធិខ្មែរអភិវឌ្ឍន៍<br>- ជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារ ផ្លូវថ្នល់ លូទឹក និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិចចំនួន១១គ្រឿង<br>- ជួសជុលសម្ភារៈការិយាល័យ និងគ្រឿងសង្ហារឹម ចំនួន២០គ្រឿង<br>- រៀបចំកែលម្អបរិស្ថានក្នុងបរិវេណព្រឹទ្ធសភា ឲ្យមានសោភ័ណ្ឌភាពល្អ<br>- បិទលេខកូដសម្ភារៈសារពើភ័ណ្ឌចំនួន៤០គ្រឿង<br>- រៀបចំប្រទីបព្រឹទ្ធសភា ដើម្បីចូលរួមក្នុងពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក<br>- ចុះត្រួតពិនិត្យ តាមដានប្រព័ន្ធNetwork Internet Connect Wifi និងជួសជុលម៉ាស៊ីនកុំព្យូទ័រ ដាក់កម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធី Unicode និងSet up កម្មវិធីសរុប ចំនួន២២គ្រឿង។ បានUpload សេចក្តីជូនដំណឹង ព្រឹត្តិបត្រព័ត៌មានសុខភាព ទស្សនាវដ្តី និងរូបភាព សកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភាសរុបចំនួន១៧៧ ចំណងជើង។<br>+ការងារផ្សេងៗ:<br>- ថត និងផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំក្នុងកម្មវិធីផ្សេងៗចំនួន១៩លើក<br>- បានរៀបចំ និងបញ្ចូលលេខកូដឯកសារសៀវភៅច្បាប់ |

| | |
|---|---|
| | សៀវភៅជំនាញផ្សេងៗ និងចុះបញ្ជីឯកសារបោះត្រា បិទប័ណ្ណខ្នី និងសងសៀវភៅ ជួសជុល និងផ្លាស់ប្តូរលេខកូដចាស់ៗសរុបចំនួន៨៦ក្បាល<br>- បញ្ចូលទិន្នន័យសៀវភៅព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ច្បាប់ កាសែត ទស្សនាវដ្តី ព្រឹត្តិបត្រ រាជកិច្ច ដាក់លេខកូដសៀវភៅថ្មី និងបញ្ចូលសៀវភៅតាម PMB E-Library បណ្តាញ Facebook សរុបចំនួន៥,២៤២ ក្បាល ។ |

**II.ទិសដៅការងារខែធ្នូ ឆ្នាំ២០១៧**

**១.មុខងារនីតិកម្ម**:

-ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រជុំពេញអង្គលើកទី១១ ព្រឹទ្ធសភា នីតិកាលទី៣

-ត្រៀមបោះពុម្ពសៀវភៅច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ដែលបានធ្វើវិសោធនកម្ម (បកប្រែជាភាសាបារាំង និងអង់គ្លេស)

-ត្រៀមបោះពុម្ពសៀវភៅច្បាប់ស្តីពី លក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ

-បន្តរៀបចំបទបញ្ជាផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រមសីលធម៌សម្រាប់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបច្ចុប្បន្នភាពគោលការណ៍ គោលនយោបាយនានា។

**២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា** :

-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការជំនាញ និងក្រសួងស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្តាខេត្ត ក្រុង ។

**៣.មុខងារតំណាង** :

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចូលរួមក្នុងពិធីផ្លូវការនានា នៅតាមបណ្តាខេត្ត ក្រុង

-ត្រៀមរៀបចំវេទិកាតាមភូមិភាគ សិក្ខាសាលា និងពិធីសំណេះសំណាលផ្លូវការផ្សេងៗ

-ត្រៀមចូលរួមប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិ (ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៧)

-ត្រៀមទទួលមន្ត្រីរាជការ យុវជន សិស្ស និស្សិត និងសាធារណជនមកទស្សនកិច្ចនៅព្រឹទ្ធសភា។

**៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ** :

-ត្រៀមរៀបចំពិធីទទួលឯកអគ្គរដ្ឋទូតប្រទេសនានា

-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំ ក្នុងនាមជាប្រធានព្រឹទ្ធសភា ជាមួយគណៈប្រតិភូបរទេស (នាយករដ្ឋមន្ត្រី Bangladesh និងអនុប្រធានព្រឹទ្ធសភាឆែក)

-ត្រៀមទទួលដំណើរទស្សនកិច្ចគណៈប្រតិភូអគ្គលេខាធិការព្រឹទ្ធសភាប៉ាគីស្ថាន(ខែមករា ឆ្នាំ២០១៨)

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស

-មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១៥នាក់ ចូលរួមវគ្គ Advance English Program នៅព្រះរាជាណាចក្រថៃឡង់ដ៍

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា

-តាមដានគម្រោងសុំជំនួយពីប្រទេសជាមិត្តសម្រាប់នីតិកាលទី២

-ត្រៀមសហប្រតិបត្តិការរវាងវិទ្យាស្ថានសភាកម្ពុជា (PIC), (IPU), (APF)

-រៀបចំការបណ្តុះបណ្តាលអ្នកស្រាវជ្រាវខាងទំនាក់ទំនងអន្តរជាតិ

-ត្រៀមបែបបទទទួលជំនួយពីរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម

-ការអនុវត្ត MOU សហប្រតិបត្តិការជាមួយព្រឹទ្ធសភាឥណ្ឌា និងប៉ាគីស្ថាន និងផ្តល់ចម្លើយទៅភាគីឥណ្ឌាអំពីការបង្កើតអគ្គនាយកដ្ឋានស្រាវជ្រាវ ។

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

-បន្តរៀបចំជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ និងបំពាក់សម្ភារៈប្រើប្រាស់រួមមាន៖ អគារសាលប្រជុំពេញអង្គ បំពាក់សម្ភារៈថ្មី អគារការិយាល័យសមាជិកព្រឹទ្ធសភា ព្រមទាំងរៀបចំគូសគំនូស ចំណតរថយន្ត និងស្លាកសញ្ញាបង្ហាញផ្លូវ (ផ្នែកខាងជើង)

-ការងារតាមដានការសុំជំនួយពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន រួមមានការកសាងអគារសាលប្រជុំពេញអង្គថ្មី សម្ភារៈបរិក្ខារអេឡិចត្រូនិច និងរថយន្ត

-បង្កើនការគ្រប់គ្រងអគារ និងសារពើភ័ណ្ឌ ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ ការសន្សំសំចៃទឹក ភ្លើង ការគ្រប់គ្រងការប្រើប្រាស់ Internet

-ការសិក្សារៀបចំ TV- online របស់ព្រឹទ្ធសភា និងបង្កើនការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការងារប្រចាំថ្ងៃ

-ការចាប់ផ្តើមរៀបចំប្រព័ន្ធ Website/Webpage ក្នុងកម្រិតអគ្គនាយកដ្ឋាន និងគណៈកម្មការ

-បង្កើនសមត្ថភាពស្រាវជ្រាវលើគ្រប់វិស័យ ដើម្បីបង្កើនសមត្ថភាពផ្តល់សេវាព័ត៌មានចាំបាច់

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល គ្រប់គ្រងបុគ្គលិកតាមប្រព័ន្ធព័ត៌មានវិទ្យា កសាងProgram និងSoftware ដើម្បីអនុវត្តតាមអង្គភាព និងការបណ្តុះបណ្តាល ក្នុងនោះចូលអនុវត្តកម្មវិធី E បណ្ណាល័យ និងE បណ្ណសារ

-បន្តប្រជុំគណៈកម្មការពិនិត្យ និងកែសម្រួលបទបញ្ជាផ្ទៃក្នុង ក្រមសីលធម៌មន្ត្រីរាជការ និងផ្តល់ចម្លើយទៅភាគីឥណ្ឌា

-បន្តប្រជុំពិនិត្យអំពីលក្ខន្តិកៈសមាគមសង្គហៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ

-សិក្សាអំពីការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តិ បម្រើឲ្យការគ្រប់គ្រងក្នុងបរិបទកំណែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-ទំនាក់ទំនងជាថ្មីជាមួយភាគីវៀតណាម ដើម្បីបន្តអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន(ICT) និងការបំពាក់សម្ភារៈបរិក្ខារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (ដំណាក់កាលទី២ )

-ជំរុញការស្នើសុំអាហារូបករណ៍ និងដាក់ពាក្យប្រលងអាហារូបករណ៍ពីប្រទេសផ្សេងៗទៀត (ឆ្នាំ២០១៨ )

-ផ្សព្វផ្សាយក្របខ័ណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានឆ្នាំ(២០១៨-២០២៤)

-ការបូកសរុបលទ្ធផលការងារនីតិកាលទី៣ និង៣នីតិកាល

-ការផលិតខ្សែVD ៥ខ្សែ ដើម្បីបូកសរុបសមិទ្ធផលរបស់ព្រឹទ្ធសភា

-ការបោះពុម្ពដំណាច់ឆ្នាំ ទិនានុលេខន៍ និងប្រតិទិន

-រៀបចំផែនការថវិកាតាមកម្មវិធីឆ្នាំ២០១៨ និងរៀបចំបែងចែកឥណទានព្រឹទ្ធសភាឆ្នាំ២០១៨

-រៀបចំផែនការប្រតិបត្តិឆ្នាំ២០១៨ និងបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ១០ឆ្នាំ

-ត្រៀមធ្វើជំរឿនសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និងតម្រូវការ

-ត្រៀមរៀបចំគោលការណ៍ហិរញ្ញវត្ថុសម្រាប់នីតិកាលថ្មី ។

III.**សេចក្តីសន្និដ្ឋាន**

ក្នុងខែវិច្ឆិកានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានរៀបចំ និងចាត់ចែងការងារជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភាបានយ៉ាងល្អប្រសើរ ។ ជាមួយគ្នានេះ ព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្ម លើសេវាទ្រទ្រង់មុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង ។ ច្បាប់សំខាន់ៗ ត្រូវបានអនុម័តពាក់ព័ន្ធថវិកាឆ្នាំ២០១៨ និងបានទូទាត់ថវិកាឆ្នាំ២០១៦ ។ សកម្មភាពការងារប្រចាំថ្ងៃ មានភាពមមាញឹក និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភាបានដោយរលូន ។ ការអភិវឌ្ឍស្ថាប័ន បានបន្តយកចិត្តទុកដាក់ខ្ពស់លើការអភិវឌ្ឍ ធនធានមនុស្ស និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានថ្មីៗ ដើម្បីធានាបាននូវសេវាគ្រប់ប្រភេទប្រកបដោយគុណភាពខ្ពស់ជូនអតិថិជនរបស់ខ្លួន ។ ការងារសហប្រតិបត្តិការអន្តរជាតិ បានឆ្លុះ បញ្ចាំងឲ្យឃើញនូវសូចនាករវិជ្ជមាននៃការកៀរគរដៃគូឧបត្ថម្ភគាំទ្រជំនួយពីគ្រប់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ សំដៅអភិវឌ្ឍន៍ធនធានមធ្យោបាយ និងហេដ្ឋារចនាសម្ព័ន្ធឲ្យកាន់តែសម្បូរបែប ទំនើប និងទាន់ការវិវត្តឥតឈប់ឈរនៃបច្ចេកវិទ្យារួមទាំងការរីកចម្រើនក្នុងតំបន់ និងពិភពលោក ។ ជាពិសេសវគ្គអំពីទំនាក់ទំនងអន្តរជាតិ បានចាប់

ផ្តើមចេញដំណើរ ។ ការរក្សាស្ថានភាពនៃសហប្រតិបត្តិការជាមួយ ដៃគូគ្រប់ប្រភេទនៅតែរក្សាបានជាមូលដ្ឋាន។ ជំនួយសម្រាប់នីតិកាលទី៤ បានចាប់ផ្តើមមកដល់ នាពេលខាងមុខនេះ ។

ថ្ងៃសុក្រ ៥រោច ខែមិគសិរ ឆ្នាំរកា ព.ស ២៥៦១

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែធ្នូ គ.ស ២០១៧

**អគ្គលេខាធិការ**

អ៊ុំ សារិទ្ធ